**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚ ✥ ៚

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៦០៤ អយក.ប្រក

# ប្រកាស

ស្ដីពី ការបើកសាលាបឋមសិក្សា **ភូមិតាប៉ុម**

ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **ចំការអណ្ដូង**

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា ។

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្ដីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតលេខ ០២១ ចក.ចអ របស់ប្រធាន អគ្គនាយកចំការកៅស៊ូ ចំការអណ្ដូង និង ចំណោរឯកភាពរបស់មន្ទីរអប់រំ យុវជន និង កីឡាខេត្តកំពង់ចាម ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០០៣

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

**សំរេច**

__ប្រការ១__ : បើកសាលាបឋមសិក្សា **ភូមិតាប៉ុម** ដែលមានទីតាំងស្ថិតនៅភូមិ **តាប៉ុម** ឃុំ **ចំការអណ្ដូង** ស្រុក **ចំការលើ** ខេត្ត **កំពង់ចាម** ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **ចំការអណ្ដូង** ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

__ប្រការ២__ : សាលាបឋមសិក្សា **ភូមិតាប៉ុម** ត្រូវមានប្រធានក្រុម ម្នាក់ទទួលខុសត្រូវ រួមជាមួយនាយក សាលាបឋមសិក្សា **ចំការអណ្ដូង** ។

__ប្រការ៣__ : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡាខេត្ត **កំពង់ចាម** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ចំការលើ** នាយកសាលាបឋមសិក្សា **ចំការអណ្ដូង** និង ប្រធានក្រុមសាលាឧបសម្ព័ន្ធ **ភូមិតាប៉ុម** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម សិទ្ធី**

**កន្លែងទទួល**

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **កំពង់ចាម**

" __**ដើម្បីជូនជ្រាបជាពត៌មាន**__ "

-ដូចប្រការ ៣

-កាលប្បវត្តិ-ឯកសារ នា.បស